**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង

នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង ១៤.00នាទី នៅក្នុង**រោងចក្រ ហុង វ័ន** (**ខេមបូឌា**) **ហ្គាមេន** មានកិច្ចប្រជុំមួយ រវាងគណៈប្រតិភូបុគ្គលិកនិង តំណាងកម្មករនិយោជិតប្រចាំរោងចក្រ ។

ដោយសារតែក្រុមហ៊ុនយើងត្រូវបានលុបការបញ្ជាទិញពីអតិថិជន និងគ្មានការបញ្ជាទិញ ក្នុងអំឡុងពេលផ្ទុះមេរោគឆ្លងជាសាកល កូវីដ-១៩ ដូចនេះនាយក**ក្រុមហ៊ុន ហុង វ័ន** (**ខេមបូឌា**) **ហ្គាមេន** និងកម្មករនិយោជិត ទាំងអស់បានព្រមព្រៀងគ្នាដូចខាងក្រោមៈ

- ឯកភាពព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ៧១៩នាក់ រយៈពេល ១៩ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១២ **ខែមិថុនា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០**។

- ក្នុងកំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះ ក្រុមហ៊ុនបានព្រមព្រៀងផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិត ២០ដុល្លា ក្នុងកំឡុងពេលព្យួរការងារសម្រាប់កម្មករនិយោជិតម្នាក់ៗ ចំណែក៣០ដុល្លាផ្សេងទៀត គឺឧបត្ថមពីសម្តេច (អនុវត្តតាមសេចក្តីជូនដំណឹងលេខ ០៤៥ )។

- ថ្ងៃធ្វើការពីថ្ងៃទី **០១ ខែមិថុនា ឆ្នាំ ២០២០ រហូតដល់ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០២០** រាល់អត្ថប្រយោជន៍ផ្សេងៗ ដូចជា (សោហ៊ុយធ្វើដំណើរ, លុយរង្វាន់ធ្វើការទៀងទាត់, រង្វាន់ជាប់ការសាកល្បង, លុយរង្វាន់ធ្វើការថែមម៉ោង នឹងលុយរង្វាន់ពិសេស គឺគិតជាសមាមាត្រ)។

-បើកប្រាក់ឈ្នួល នៅថ្ងៃទី ០៩ ខែកក្កដា (បើកតាមវីង និងធនាគារ )

អង្គប្រជុំបានចប់វេលា ម៉ោង១៥ និង ៣០នាទី នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងមានភាពស្និតស្នាល និងក្រោមបរិយាកាសដ៏រីករាយ។

គណៈប្រតិភូបុគ្គលិក **នឹងតំណាងកម្មករនិយោជិត** បានឃើញនិងឯកភាព

ភ្នំពេញ ថ្ងៃទី 28 ខែឧសភា ឆ្នាំ 2020

ហត្ថលេខា និងត្រា
នាយកក្រុមហ៊ុន

-ឆាយ ម៉ុក -ជុំ សំអឿន - សុំ សុភណ្ឌ៉ា -លី ស្រីលីន

-សួន ស្រីខួច - ហោ វាសនា -ឈួន ម៉ាលិស - ឡាញ សាវ៉ាន់

-ញ៉ែម សុខលី - ភួង ពេជ្រ - អ៊ុន សារឹម -តាំង ដារី

ព្រះរាជាណាចក្រកម្ពុជា
ហុង វ័ន (ខេមបូឌា) ហ្គាមេន
HONGS ONE (CAMBODIA) GARMENT
ស្នាក់ការរាជធានីភ្នំពេញ

Chan Kuok Wai